នស/រកត/០៣០៨/៣៤៦

# ព្រះរាជក្រឹត្យ

## ស្ដីពី

## គោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការ
## ទីភ្នាក់ងារប្រតិបត្តិការពិសេស

---

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់នូវគោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស សរសេរកាត់ថា "ទ.ប.ព." ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

**មាត្រា ២.-**

ការងារទីភ្នាក់ងារប្រតិបត្តិការពិសេស គឺជាយន្តការនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន ដែលរួមបញ្ចូលគ្នានូវមុខងារផ្សេងៗ ដើម្បីឱ្យទីភ្នាក់ងារនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប្រទាក់ក្រឡាគ្នា ស៊ីសង្វាក់គ្នា និងមានសង្គតិភាពនឹងគ្នាជាមួយយន្តការដទៃទៀតនៃការអនុវត្តសេវាសាធារណៈ សម្រាប់ផ្តល់សេវាដែលបានកំណត់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវបានរៀបចំឡើង ក្នុងគោលបំណង :

- កែលំអគុណភាព និងផ្តល់សេវាសាធារណៈនៅគ្រប់ទីកន្លែង និងពេលវេលា ដែលត្រូវការ
- កែប្រែផ្នត់គំនិត និងអាកប្បកិរិយាមន្ត្រី ស្របតាមលក្ខណៈសម្បត្តិរបស់រដ្ឋបាលសាធារណៈ គឺមានទឹកចិត្តបម្រើការងារមោះមុត ភក្តីភាព ផ្តោតលើសេវា និងមានសីលធម៌វិជ្ជាជីវៈ
- លើកកម្ពស់ការគ្រប់គ្រងផ្អែកលើលទ្ធផលការងារ ដោយភាពប្រុងប្រយ័ត្ន មានប្រសិទ្ធភាព និងមានតម្លាភាព
- អភិវឌ្ឍសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈ។

## ជំពូកទី ២
## លក្ខណៈសម្បត្តិ នៃទីភ្នាក់ងារប្រតិបត្តិការពិសេស

**មាត្រា ៤.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស គឺជាភ្នាក់ងារមួយរបស់ក្រសួង ស្ថាប័ន ដែលមានរចនាសម្ព័ន្ធដោយឡែកពីអង្គភាពដទៃទៀតរបស់ក្រសួង ស្ថាប័នសាមី ។

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវមានលក្ខណៈសម្បត្តិចម្បងៗ ដូចខាងក្រោម :

- នីតិវិធី និងការិយាធិបតេយ្យនៅក្នុងដំណើរការនៃការផ្តល់សេវាជូនអ្នកប្រើប្រាស់សេវា ត្រូវបានកាត់បន្ថយ
- ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវបានទទួលសិទ្ធិលើការងារគ្រប់គ្រងទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកធនធានមនុស្ស
- ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពលើការងារ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ្រប់គ្រង និងលទ្ធផលរំពឹងទុក ចំពោះក្រសួង ស្ថាប័នសាមី

- ត្រូវមានលក្ខខណ្ឌបេសកកម្ម កិច្ចសន្យាគ្រប់គ្រង និងរបាយការណ៍ច្បាស់លាស់ ។

**មាត្រា ៥.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវមានលក្ខខណ្ឌបេសកកម្មដែលត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី គោលដៅ គោលបំណង តួនាទី មុខងារ លទ្ធផលរំពឹងទុក ប្រភេទសេវាដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់សេវា គោលការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការទទួលខុសត្រូវ និងគណនេយ្យភាព ក្នុងការគ្រប់គ្រងការបំពេញការងាររបស់ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ព្រមទាំងសមត្ថកិច្ចសមស្របដទៃទៀត ដែលក្រសួង ស្ថាប័នផ្តល់ឱ្យ ។

**មាត្រា ៦.-**

ក្នុងក្របខ័ណ្ឌនៃលក្ខខណ្ឌបេសកកម្ម ប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវធ្វើកិច្ចសន្យាគ្រប់គ្រងប្រចាំឆ្នាំជាមួយនឹងប្រធានស្ថាប័នសាមី ។ ក្នុងកិច្ចសន្យាគ្រប់គ្រង ត្រូវបញ្ជាក់ពីលទ្ធផលដែលអាចវាស់វែង ឬវាយតម្លៃបាន ធៀបទៅនឹងសូចនាករលទ្ធផលផងដែរ ។ កិច្ចសន្យាគ្រប់គ្រង ត្រូវមានចុះហត្ថលេខាព្រមព្រៀងរវាងប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស និងរដ្ឋមន្ត្រី ឬ តំណាងក្រសួង ស្ថាប័នសាមីនោះ ។

ក្នុងកិច្ចសន្យាគ្រប់គ្រងត្រូវកំណត់អំពី :

- មុខសញ្ញា ប្រភេទសេវា និងស្តង់ដារគុណភាពសេវា ដែលទីភ្នាក់ងារប្រតិបត្តិការពិសេសធានាផ្តល់ជូនអ្នកប្រើប្រាស់សេវា
- តម្លៃសេវា និងពេលវេលាដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់សេវា
- សកម្មភាពការងារសំខាន់ៗដែលទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវអនុវត្ត
- ធនធានដែលទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវការជាចាំបាច់
- សូចនាករនៃលទ្ធផលរំពឹងទុក
- បែបបទ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- បទបញ្ជាផ្ទៃក្នុង
- របបធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័ន សាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- ការលើកទឹកចិត្ត និងការដាក់វិន័យ ។

**មាត្រា ៧.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវធ្វើរបាយការណ៍ការងារ របាយការណ៍សវនកម្ម របាយការណ៍វាយតម្លៃ ជាទៀងទាត់ជូនទៅក្រសួង ស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *

## ជំពូកទី ៣
## ការគ្រប់គ្រងសកម្មភាពការងារ

**មាត្រា ៨.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវមានទីតាំងសមស្របដើម្បីបង្កលក្ខណៈឱ្យអ្នកប្រើប្រាស់សេវាងាយស្រួលចូលទៅទាក់ទងស្នើសុំ និងទទួលយកសេវា។

ទីភ្នាក់ងារនេះត្រូវមានផ្នែកផ្តល់សេវាជួរមុខដែលជួបផ្ទាល់ជាមួយនឹងអ្នកប្រើប្រាស់សេវា និងអាចមានអង្គភាពទ្រទ្រង់ ដើម្បីជួយគាំទ្រដល់ផ្នែកជួរមុខដែលមានមុខងារចម្រុះដូចជា មុខងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស និងគ្រប់គ្រងហិរញ្ញវត្ថុ។ រចនាសម្ព័ន្ធនៃទីភ្នាក់ងារនេះ ត្រូវមានលក្ខណៈទន់ភ្លន់ និងងាយបត់បែនបានដើម្បីសម្រេចបាននូវតម្រូវការប្រតិបត្តិការ។

**មាត្រា ៩.-**

ក្រសួង ស្ថាប័នសាមី ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យាគ្រប់គ្រងរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសឱ្យមានប្រសិទ្ធភាព។

រាល់សកម្មភាពរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវផ្តោតទៅលើស្នាដៃបំពេញការងារ ធៀបទៅនឹងលទ្ធផលរំពឹងទុក។

**មាត្រា ១០.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវរៀបចំកិច្ចសន្យាការងាររបស់មន្ត្រីម្នាក់ៗទៅតាមកម្រិតឋានានុក្រម ដោយមានបញ្ជាក់នៅក្នុងកិច្ចសន្យានីមួយៗអំពីការទទួលខុសត្រូវដែលបានប្រគល់ឱ្យជាឯកត្តជនក្នុងការសម្រេចលទ្ធផលរំពឹងទុករបស់ខ្លួន។

មន្ត្រីរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវបានវាយតម្លៃជាទៀងទាត់ ស្របតាមផែនការសកម្មភាពការងារ តាមរយៈកិច្ចសន្យាការងារ។

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវធ្វើរបាយការណ៍ឱ្យបានទៀងទាត់តាមការកំណត់នៅក្នុងកិច្ចសន្យាគ្រប់គ្រង និងលក្ខខណ្ឌបេសកកម្ម ។

## ជំពូកទី ៤
## ការគ្រប់គ្រងបុគ្គលិក

**មាត្រា ១១.-**

ទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវដឹកនាំគ្រប់គ្រងដោយប្រធានមួយរូប និងមានបុគ្គលិកបម្រើការងារជាមន្ត្រីរាជការសាធារណៈ ឬ មន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ស្ថាប័នសាមី។ ការគ្រប់គ្រងបុគ្គលិកត្រូវយកចិត្តទុកដាក់ជាពិសេសលើ :

ROYAUME DU CAMBODGE • LE MINISTRE ... PALAIS ROYAL •

- លទ្ធផលការងារ
- តម្លាភាព និងសីលធម៌វិជ្ជាជីវៈ
- គណនេយ្យភាពជាលក្ខណៈបុគ្គល និងជាក្រុម
- ការលើកកម្ពស់សមត្ថភាពប្រតិបត្តិការ ។

**មាត្រា ១២.–**

ទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវមានសមត្ថកិច្ច និងភារកិច្ចនៅក្នុងក្របខ័ណ្ឌដឹកនាំ និងគ្រប់គ្រងធនធានមនុស្សដែលមានចែងក្នុងច្បាប់ និងបទដ្ឋានគតិយុត្ត ស្តីពីការគ្រប់គ្រងមុខងារសាធារណៈ ដូចជា ការជ្រើសរើសមន្ត្រី ការលើកទឹកចិត្ត និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យា និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាគ្រប់គ្រង ។

**មាត្រា ១៣.–**

មន្ត្រីមុខងារសាធារណៈដែលបម្រើការងារក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេស មានលាភការជាប្រាក់បៀវត្សរ៍ និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍ រួមផ្សំនឹងប្រាក់លើកទឹកចិត្តផ្សេងៗដែលមានចែងបញ្ជាក់ក្នុងកិច្ចសន្យាការងារ ។

ចំពោះលាភការរបស់មន្ត្រីជាប់កិច្ចសន្យា នឹងត្រូវកំណត់នៅក្នុងបទដ្ឋានមួយដោយឡែក ។

**មាត្រា ១៤.–**

មន្ត្រីដែលបម្រើការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវចុះកិច្ចសន្យាការងារជាមួយប្រធានទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលរួមមាន :

- ការគោរពបទបញ្ជាផ្ទៃក្នុង
- ការបំពេញការងារដែលបានប្រគល់ជូនដោយមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះមុខតំណែងរបស់ខ្លួន
- ការបញ្ជាក់ច្បាស់លាស់អំពីបញ្ជីសកម្មភាពការងាររបស់ខ្លួន
- របាយការណ៍លទ្ធផលការងារ
- ការលើកទឹកចិត្ត និងការដាក់វិន័យ ។

## ជំពូកទី ៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៥.–**

ទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវមាន :

- ថវិកាប្រតិបត្តិការដែលអាចព្យាករណ៍បាន និងមានស្ថិរភាព
- អភិក្រមត្រឹមត្រូវក្នុងបរិបទច្បាប់ជាធរមាន
- តម្លាភាព និងរបាយការណ៍ទៀងទាត់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦.–**

ថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស គឺជាផ្នែកមួយនៃថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន សាមី ។

ក្រសួង ស្ថាប័នសាមី និងក្រសួង ស្ថាប័ពាក់ព័ន្ធ ត្រូវកំណត់ និងធានានូវថវិកាដែលត្រូវផ្តល់ឱ្យទីភ្នាក់ងារប្រតិបត្តិការពិសេសទាន់ពេលវេលា ។ ការរៀបចំថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវផ្អែកទៅលើកម្មវិធីការងារដែលបានគ្រោងទុក ។

**មាត្រា ១៧.–**

ប្រភពធនធាន និងចំណូលថវិការបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស មានជាអាទិ៍ ពី :

- ថវិកាជាតិ
- ការបែងចែកកម្រៃសេវា
- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍
- ប្រភពផ្សេងៗទៀត ។

**មាត្រា ១៨.–**

ទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវមានសមត្ថកិច្ច និងកាតព្វកិច្ចសំខាន់ៗ ដូចជា :

- រៀបចំផែនការចំណាយប្រចាំឆ្នាំរបស់ខ្លួន
- មានស្វ័យភាពក្នុងការចំណាយ ស្របតាមផែនការ និងគោលការណ៍ដែលបានកំណត់
- មាននីតិវិធីចំណាយត្រឹមត្រូវ ។

**មាត្រា ១៩.–**

ការកំណត់តម្លៃសេវា និងការបែងចែកកម្រៃសេវា ត្រូវធ្វើឡើងទៅតាមស្ថានភាពជាក់ស្តែងនៃទីកន្លែងដែលទីភ្នាក់ងារប្រតិបត្តិការពិសេសស្ថិតនៅ តាមប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួង ស្ថាប័ន សាមី ។

**មាត្រា ២០.–**

ការគ្រប់គ្រង ការត្រួតពិនិត្យ អធិការកិច្ច ការធ្វើសវនកម្មរាល់ការចំណូលចំណាយ និងដំណើរការការងារ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និងបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ៦
## ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន

**មាត្រា ២១.–**

ក្រសួង ស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កលក្ខណៈឱ្យទីភ្នាក់ងារប្រតិបត្តិការពិសេសអាចប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចក្នុងការទំនាក់ទំនង ដើម្បីសម្រួលដល់ការស្នើសុំ និងការផ្តល់សេវាជូនអ្នកប្រើប្រាស់សេវាឱ្យកាន់តែរហ័ស និងមានតម្លាភាព ។

មាត្រា ២២.-

ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ត្រូវរៀបចំឡើងដើម្បីពង្រឹងអភិក្រមផ្ទៃក្នុងរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេសផងដែរ ដូចជាត្រូវមានវិធានការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឱ្យមានប្រសិទ្ធភាពក្នុងការគាំទ្រដល់ការគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ទីភ្នាក់ងារ ។

## ជំពូកទី ៧

## ការបង្កើត និងការចាត់តាំង

មាត្រា ២៣.-

ក្រសួង ស្ថាប័នសាមី ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់យន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស ដើម្បីកែលំអការផ្តល់សេវារបស់ក្រសួង ស្ថាប័ន ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា ។

មាត្រា ២៤.-

ទីស្តីការគណៈរដ្ឋមន្ត្រីមានតួនាទីសម្របសម្រួល ជំរុញ និងដាក់ឱ្យអនុវត្តទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ និងតាមដានការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេសទាំងនោះ ។

មាត្រា ២៥.-

ការបង្កើត និងការដាក់ឱ្យអនុវត្តទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ដោយមានភ្ជាប់នូវខ្លឹមសារគោលជារួមនៃលក្ខខណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រង ជាឧបសម្ព័ន្ធ ។

ការចាត់តាំងប្រធាន និងបុគ្គលិកទីភ្នាក់ងារប្រតិបត្តិការពិសេសនីមួយៗ ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងអនុក្រឹត្យនៃការបង្កើតទីភ្នាក់ងារប្រតិបត្តិការពិសេសនោះ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

មាត្រា ២៦.-

គ្រឹះស្ថានសាធារណៈដែលកំពុងដំណើរការ មិនអាចផ្លាស់ប្តូរទៅជាទីភ្នាក់ងារប្រតិបត្តិការពិសេសបានទេ ។

ROYAUME DU CAMBODGE

**មាត្រា ២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៨.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ៥១ ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩ល.០៩០៣.៣៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:៣៤៥ ច.ល

**ចម្លងចេញពីច្បាប់ដើម**

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ០១ ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**